00364605

D164/4/3

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 20 / 08 / 2009
ម៉ោង (Time/Heure): 09:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: C.A.Fuy

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire

**សំណុំរឿងព្រហ្មទណ្ឌលេខ:** ០០២/១៩-០៩-២០០៧/អវតក/កសចស (អបជ២៤ និង២៥)

**ចំពោះមុខ:**
ចៅក្រម ប្រាក់ គឹមសាន, ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម ន៉យ ថុល
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

**កាលបរិច្ឆេទ:** ថ្ងៃទី២០ ខែសីហា ឆ្នាំ២០០៩

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date /Date de certification): 20 / 08 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: C.A.Fuy

---

**សាធារណៈ:**

**សេចក្តីសម្រេចលើ "សំណើសុំបើកសវនាការសួរដេញដោលផ្ទាល់មាត់" លើបណ្តឹងឧទ្ធរណ៍ អបជ២៤ និងអបជ២៥**

---

**សហព្រះរាជអាជ្ញា**
ជា លាង
Robert PETIT

**ជនត្រូវចោទ**
អៀង សារី
នួន ជា
អៀង ធីរិទ្ធ
ខៀវ សំផន

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**
ហុង គឹមសួន
ឡោ ជុនធី
នី ចាន់ឌី
គង់ ពិសី
យុង ផានិត
គឹម ម៉េងឃី
ម៉ុច សុវណ្ណារី
Silke STUDZINSKY
Martine JACQUIN
Philippe CANONNE
Pierre Olivier SUR
Elizabeth RABESANDRATANA
Olivier BAHOUGNE
David BLACKMAN
Annie DELAHAIE

**សហមេធាវីការពារក្តី**
**មេធាវីការពារក្តី អៀង សារី៖**
អាង ឧត្តម
Michael G. KARNAVAS
**មេធាវីការពារក្តី នួន ជា៖**
សុន អរុណ
Victor KOPPE

អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C.* C.E.T.C.

Michiel PESTMAN

**មេធាវីការពារក្តី អៀង ធីរិទ្ធ៖**

ផាត់ ពៅស៊ាង

Diana ELLIS

**មេធាវីការពារក្តី ខៀវ សំផន៖**

ស សូវ៉ាន

Jacques Verges

**សហចៅក្រមស៊ើបអង្កេត**

យូ ប៊ុនឡេង

Marcel Lemonde

**ដើមបណ្តឹងរដ្ឋប្បវេណីគ្មានមេធាវីតំណាង**

00364607



១. **អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា "អ.វ.ត.ក" កត់សម្គាល់ចំពោះ សំណើរបស់សហមេធាវីការពារក្តី អៀង ធីរិទ្ធ, នួន ជា និង ខៀវ សំផន ស្នើសុំបើកសវនាការសួរ ដេញដោលផ្ទាល់មាត់ (សំណើសុំ) ចំពោះ "បណ្តឹងឧទ្ធរណ៍រួមរបស់មេធាវីការពារក្តី ប្រឆាំងនឹង ដីកាសម្រេចរបស់ ក.ស.ច.ស ស្តីពីសំណើសុំបំពេញកិច្ចស៊ើបសួរ ដើម្បីស្វែងរកភស្តុតាងដោះ បន្ទុកនៅក្នុងឃ្លាំងផ្ទុកឯកសាររួមក្នុងកំព្យូទ័រ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៩" ដែលដាក់នៅថ្ងៃទី ២៤ ខែកក្កដា ឆ្នាំ២០០៩ ("បណ្តឹងឧទ្ធរណ៍")[១]។

២. នៅក្នុងសំណើសុំរបស់ខ្លួន សហមេធាវីការពារក្តី សូមស្នើឱ្យមានការកំណត់កាលបរិច្ឆេទសវនាការ ដើម្បីអនុញ្ញាតឱ្យភាគីពាក់ព័ន្ធ "បានបំភ្លឺបញ្ហានេះ"។

៣. នៅក្នុងចម្លើយតបរួមរបស់ខ្លួនទៅនឹងបណ្តឹងឧទ្ធរណ៍ សហព្រះរាជអាជ្ញាសន្និដ្ឋានថា បណ្តឹងឧទ្ធរណ៍ ទាំងនេះមិនបានលើកបញ្ហាច្បាប់ដ៏ស្មុគស្មាញ ឬសំខាន់នានាទេ ប៉ុន្តែវាគ្រាន់តែមាន "លក្ខណៈ សាមញ្ញ និងភាគច្រើនជាបញ្ហាបច្ចេកទេស" តែប៉ុណ្ណោះ អាស្រ័យហេតុនេះបណ្តឹងឧទ្ធរណ៍ គួរត្រូវ បានសម្រេច ដោយផ្អែកលើមូលដ្ឋាននៃសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរតែប៉ុណ្ណោះ ដើម្បី ចំណេញផលប្រយោជន៍សេដ្ឋកិច្ចតុលាការ[២]។

៤. វិធាន៧៧ នៃវិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៣) ចែងអំពីផ្នែកពាក់ព័ន្ធ៖

---

[១] "បណ្តឹងឧទ្ធរណ៍រួមរបស់មេធាវីការពារក្តី ប្រឆាំងដីកាសម្រេចរបស់ កសចសស្តីពីសំណើសុំបំពេញកិច្ចស៊ើបសួរដើម្បីស្វែងរក ភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុកឯកសាររួមក្នុងកុំព្យូទ័រ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៩" ដែលដាក់នៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៩ ("បណ្តឹងឧទ្ធរណ៍"), D164/4/1 កថាខណ្ឌ៨-៩។

[២] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ, នួន ជា, ខៀវ សំផន និងអៀង សារី ប្រឆាំង នឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ដែលបដិសេធសំណើរួមរបស់មេធាវីការពារក្តី សុំឱ្យបំពេញកិច្ចស៊ើបសួរដើម្បី ស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុកឯកសាររួមក្នុងកុំព្យូទ័រ ថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៩ ("ចម្លើយតបរបស់សហព្រះរាជ អាជ្ញា"), D164/4/2, កថាខណ្ឌ១២-១៦។



អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

"៣. (ខ) បន្ទាប់ពីបានពិចារណាលើការយល់ឃើញរបស់ភាគី អង្គបុរេជំនុំជម្រះអាចសម្រេចលើបណ្តឹងឧទ្ធរណ៍ ឬពាក្យសុំ ដោយផ្អែកតែលើមូលដ្ឋាន នៃសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សររបស់ភាគីតែប៉ុណ្ណោះ"។

៥. អង្គបុរេជំនុំជម្រះយល់ឃើញថា ជាវិធានទូទៅ អង្គបុរេជំនុំជម្រះពិចារណាអំពីប្រភេទពិសេស នៃបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេច បដិសេធសំណើសុំបំពេញកិច្ចស៊ើបសួររបស់សហចៅក្រមស៊ើបអង្កេត ដោយផ្អែកតែលើមូលដ្ឋាននៃសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរប៉ុណ្ណោះ។ វិធីសាស្ត្រនេះកើតមាន ដោយសារតែប្រភេទសម្ងាត់នៃការស៊ើបអង្កេត ដូចមានចែងនៅក្នុងវិធាន៥៦ នៃវិធានផ្ទៃក្នុង។ អង្គបុរេជំនុំជម្រះសង្កេតឃើញថា លទ្ធភាពនៃការបើកកិច្ចស៊ើបសួរដោយសហចៅក្រមស៊ើបអង្កេតនៅតែអាចអនុវត្ត ប្រសិនបើសំណើសុំបំពេញកិច្ចស៊ើបសួរ មិនទាន់ត្រូវបានបដិសេធជាស្ថាពរ[៣]។ នៅក្នុងការសម្រេចលើបណ្តឹងឧទ្ធរណ៍ អង្គបុរេជំនុំជម្រះអាចបដិសេធដីកាសម្រេច និងបញ្ជូនដីកានោះត្រលប់វិញសម្រាប់ពិចារណាឡើងវិញ ឬបង្គាប់ឱ្យបើកកិច្ចស៊ើបសួរដែលស្នើសុំ។ ជាវិធានទូទៅមួយ ការអនុវត្តន៍នេះជាផ្នែកមួយនៃការស៊ើបសួរ ដែលជាការណ៍សម្ងាត់។ ហេតុដូច្នេះ អង្គបុរេជំនុំជម្រះ បដិសេធសំណើសុំបើកសវនាការ។

៦. អង្គបុរេជំនុំជម្រះ អនុញ្ញាតឱ្យសហមេធាវីការពារក្តីជនត្រូវចោទ ដាក់សារណាតបជាលាយលក្ខណ៍អក្សរ ដូចមានចែងនៅក្នុងមាត្រា៨.៤ នៃសេចក្តីណែនាំអនុវត្ត អ.វ.ត.ក/០១/២០០៧/វិសោធនកម្មលើកទី៤។

៧. អង្គបុរេជំនុំជម្រះ កត់សម្គាល់បន្ថែមទៀតលើសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងការទទួលយកបានបណ្តឹងឧទ្ធរណ៍របស់ខៀវ សំផន[៤]។ អង្គបុរេជំនុំជម្រះយល់ឃើញថា វាមាន

---

[៣] សំណើសុំបំពេញកិច្ចស៊ើបអង្កេតត្រូវបានចាត់ទុកថាជាការបដិសេធជាស្ថាពរ នៅពេលដីកាសម្រេចបដិសេធកិច្ចស៊ើបសួររបស់កសចស ត្រូវបានតំកល់ដោយអង្គបុរេជំនុំជម្រះ។

[៤] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ៨-១១។



អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

លក្ខណៈសមស្រប ក្នុងការស្នើសុំមតិយោបល់របស់សហមេធាវីការពារក្តីលោក ខៀវ សំផន លើ សេចក្តីសន្និដ្ឋានទាំងនេះ។

**ហេតុដូច្នេះ អង្គបុរេជំនុំជម្រះសម្រេច÷**

(១) **បដិសេធ** សំណើសុំឲ្យសម្រេចលើបណ្តឹងឧទ្ធរណ៍ដោយផ្អែកលើមូលដ្ឋាននៃសវនាការ។

(២) **បង្គាប់ឲ្យ** សហមេធាវីការពារជនត្រូវចោទ ដាក់សារណាតបនៅក្នុងរយៈពេលកំណត់ ដូចមានចែងនៅក្នុងមាត្រា៨.៤ នៃសេចក្តីណែនាំអនុវត្ត អវតក/០១/២០០៧/វិសោធនកម្មលើកទី៤។

ភ្នំពេញ ថ្ងៃទី២០ ខែសីហា ឆ្នាំ២០០៨

**ប្រធានអង្គបុរេជំនុំជម្រះ**

**ប្រាក់ គឹមសាន**